DFID Department for International Development

# គោលការណ៍ណែនាំ
# ពីការអនុវត្តឱ្យមានប្រសិទ្ធភាពដល់
# ក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន









ម.ព.ឯ.ក AIDOC
Code: 147-032
Date:
Donated by:

# មាតិកា

**សេចក្តីផ្តើម** ............ 2

**គោលបំណង** ............ 2

-តើអ្វីទៅជាប្រព័ន្ធទឹកនៅតាមជនបទ ?............ 3

-តើធនធានវារីសត្វនៅតាមជនបទមានអ្វីខ្លះ ?............ 3

-តើក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន គឺជាអ្នកណា ? ............ 4

-មូលហេតុដែលនាំឱ្យមានគំនិតរៀបចំបង្កើតក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន......5

-តើត្រូវបង្កើតក្រុមការងារនេះយ៉ាងដូចម្តេច?............ 6

-សកម្មភាពខ្លះៗ នៃការគ្រប់គ្រងប្រព័ន្ធទឹកដោយកសិករ............ 7

-ការរៀបចំ និងការអនុវត្តផែនការសកម្មភាព............ 8

-តើស្ថានភាពនៃធនធានជលផលអាចវាយតំលៃបានយ៉ាងដូចម្តេច?............ 9

-តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីដឹងថា ការងារក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋានមានប្រសិទ្ធភាព ?... 10

-ខ្ញុំឆ្ងល់ថា តើហេតុអ្វីបានជាចាប់អារម្មណ៍ទៅលើក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ?......... 11

-គំរូនៃរបៀបវារៈ សំរាប់ការរៀបចំការប្រជុំទ្បើងទាត់ ............ 12

-ការផ្ទៀងផ្ទាត់សកម្មភាពការងារ សំរាប់ការត្រួតពិនិត្យក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន ?... 12

## សេចក្តីផ្តើម

**វារីសត្វ** គឺជាធនធានជលផលមានសារៈប្រយោជន៍បំផុតនៅតាមជនបទ ដែលមិនអាចខ្វះបានសម្រាប់ប្រជាពលរដ្ឋកម្ពុជា ពិសេសប្រជាកសិករដែលកំពុងរស់នៅតាមស្រុកស្រែចំការ តែងតែពឹងផ្អែកលើធនធានជលផលសម្រាប់ការចិញ្ចឹមជីវិតក្នុងជីវភាពគ្រួសារប្រចាំថ្ងៃ។ ធនធានជលផលបាន និងកំពុងជួយវិភាគទានដល់ការរកប្រាក់ចំណូលសំខាន់គឺបានជួយដល់ការប្រើប្រាស់ម្ហូបអាហាររបស់ប្រជាពលរដ្ឋកម្ពុជា។ ជាទូទៅ នៅតាមជនបទធនធានជលផល ត្រូវបានគេរកឃើញ ភាគច្រើនមាននៅតាមតំបន់ទំនាបក្នុងភូមិ។ សកម្មភាពនៃវារីសត្វនៅតាមតំបន់ទំនាបមានភាពសកម្មបំផុត ពិសេសគឺត្រីដែលបានធ្វើបំលាស់ទីពីកន្លែងមួយ ទៅកន្លែងមួយទៀត ដូចជា បំលាស់ទីទៅវាលស្រែ ឆ្លងកាត់ស្នាមភ្លោះ ចូលប្រឡាយ ទៅស្រះ និងចូលទៅកន្លែងផ្សេងទៀត ដែលនៅជិតតំបន់ទឹកធម្មជាតិនានា ដើម្បីធ្វើការពង កូន និងលូតលាស់នៅទីនោះ។ បើយើងគ្រប់គ្រងប្រព័ន្ធទឹកទាំងនេះបានល្អ ពិសេសប្រព័ន្ធទឹកណាដែលមិនរីងស្ងួតនៅរដូវប្រាំងនោះ នឹងធ្វើឱ្យផលត្រីមានការកើនឡើងជាលំដាប់។ ដូចនេះការបង្កើតក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន គឺជាការត្រឹមត្រូវ និងចាំបាច់បំផុតដើម្បីធានាបាននូវការរក្សា និងបង្កើនផលស្តុកធម្មជាតិ ព្រមទាំងការប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន ឱ្យមាននិរន្តរភាព។

នាយកដ្ឋានជលផលបានសហការជាមួយគម្រោង AIT- SRS (Self Recruiting Species) (ការនេសាទវារីសត្វឱ្យមាននិរន្តរភាព) ធ្វើការសិក្សាស្រាវជ្រាវរយៈពេល ៣ឆ្នាំ កន្លងមក (២០០១-២០០៤) នៅតាមជនបទ ក្នុងខេត្តស្វាយរៀង និងខេត្តតាកែវ អំពីយុទ្ធសាស្ត្រនៃការគ្រប់គ្រង និងការប្រើប្រាស់ផលត្រីធម្មជាតិរបស់ប្រជាកសិករឱ្យមាននិរន្តរភាព ។ ទីតាំងសិក្សារបស់គម្រោង គឺនៅតំបន់ខ្ពស់ក្នុងខេត្តតាកែវ និងតំបន់ទំនាបក្នុងខេត្តស្វាយរៀង ដែលស្ថិតនៅក្នុងតំបន់ **គ្មានដែនឡូត៍នេសាទ និងក្នុងដែនទឹកធម្មជាតិដទៃទៀតដែលនៅឆ្ងាយពីដែនឡូត៍នេសាទ** ។ លទ្ធផលនៃការសិក្សាក្នុងតំបន់គោលដៅរបស់គម្រោង បានបង្ហាញពីការរកឃើញយុទ្ធសាស្ត្រគ្រប់គ្រងផលត្រីធម្មជាតិរបស់ប្រជាកសិករក្នុងមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព ។ នាយកដ្ឋានជលផលបានរៀបចំបោះពុម្ពឯកសារដែលបានមកពីលទ្ធផលនៃការសិក្សានេះ ក្នុងគោលបំណងដូចខាងក្រោម :-

## គោលបំណង

ដើម្បីគ្រប់គ្រងធនធានជលផលនៅតាមជនបទ ដែលគ្មានដែនឡូត៍នេសាទឱ្យបានល្អប្រសើរ ឆ្លើយតបទៅនឹងតម្រូវការចាំបាច់នូវការប្រើប្រាស់ផលវារីសត្វរបស់ប្រជាកសិករឱ្យមានស្ថេរភាព និងនិរន្តរភាព ក្នុងគោលបំណងផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋានដល់កសិករគ្រប់តំបន់ទាំងអស់ ដើម្បីយល់ជ្រួតជ្រាប និងជួយផ្សព្វផ្សាយបន្តទៅកសិករតំបន់ដទៃទៀត ពីរបៀបគ្រប់គ្រងរួមគ្នានូវប្រព័ន្ធទឹកផ្សេងៗដែលជាកម្មសិទ្ធផ្ទាល់របស់កសិករ ដើម្បីជាផលប្រយោជន៍រួមសម្រាប់បង្កើនផលត្រីក្នុងប្រព័ន្ធទឹកគ្រប់គ្រងរបស់ខ្លួនផង និងជាប្រយោជន៍ដល់កសិករផ្សេងៗទៀត ដែលគ្មានប្រព័ន្ធទឹកសម្រាប់ចាប់ត្រីទទួលទានប្រចាំថ្ងៃ និងអាចរកប្រាក់ចំណូលពីការងារគ្រប់គ្រងប្រព័ន្ធទឹកទាំងនេះផង ។








**តើអ្វីទៅជាប្រព័ន្ធទឹក នៅតាមជនបទ ?**










---







**តើធនធានវារីសត្វនៅតាម ជនបទមានអ្វីខ្លះ ?**











## តើក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ក្នុងមូលដ្ឋាន គឺជាអ្នកណា ?

ជាគ្រួសារកសិករភាគច្រើន ដែលចូលរួមធ្វើការងារស្រុះគ្នា ក្នុងការងារគ្រប់គ្រងប្រព័ន្ធទឹក (រួមមាន ស្រះ បឿ វាលស្រែ ថ្លុក ត្រពាំង ...) ណាមួយ ក្នុងសហគមន៍ ដើម្បីបង្កើនធនធានជលផលក្នុង មូលដ្ឋាន ។





តំបន់អ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ក្នុង ភូមិស្វាយចេក ឃុំស្វាយចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង




ធនធានជលផលក្នុងមូលដ្ឋានត្រូវបានប្រើប្រាស់ ដោយកសិករដែលបានមកពីវាលស្រែរបស់ខ្លួន វាលស្រែអ្នកជិតខាង និងពីតំបន់ទឹកធម្មជាតិនានា។ ក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន អាចជួយសមាជិករបស់ខ្លួន កំណត់រកការតភ្ជាប់គ្នាពីប្រព័ន្ធទឹកនីមួយៗ ដើម្បីឱ្យចាប់បានផលត្រីដូចគ្នា ស្វែងរកវិធីគ្រប់គ្រងរួមគ្នា ហើយក៏ជួយ :

- លើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងភូមិ ឱ្យគាត់បានចូលរួមស្តាប់ចែករំលែកចំណេះដឹង និងបទពិសោធន៍ពីគ្នាទៅវិញទៅមក ។
- ជំរុញឱ្យគាត់មានការចូលរួមឱ្យបានច្រើនក្នុងចំណោមគ្រួសារកសិករ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីកែលំអការគ្រប់គ្រងធនធានជលផលឱ្យបានល្អប្រសើរ ។
-គាំទ្រប្រជាពលរដ្ឋក្នុងភូមិ និងនៅក្នុងសហគមន៍ឱ្យមានភាពទទួលខុសត្រូវខ្ពស់ក្នុងការងារគ្រប់គ្រង ។

# មូលហេតុដែលនាំឱ្យមានគំនិត
# រៀបចំបង្កើតក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន

តំបន់ខ្លះ នៅតាមវាលស្រែ ថ្លុក ត្រពាំង ឬស្រះធម្មជាតិនានា បានរីងរាក់នៅរដូវប្រាំង ហើយផលត្រីដែលចាប់បាន មានការថយចុះជាលំដាប់ ពីមួយឆ្នាំ ទៅមួយឆ្នាំ ។





ការធ្វើនេសាទខុសច្បាប់ ដោយប្រើអាគុយឆក់ ស្នៃមុង ថ្នាំបំពុល ឬ បូមបាចពង្រីងចាប់ត្រីទាំងអស់ ..។ល។

ចំនួនអ្នកនេសាទបានកើនឡើងជារៀងរាល់ឆ្នាំ ។

ផលនេសាទទាំងនេះ មិនអាចបំពេញបានតាមសេចក្តីត្រូវការរបស់ប្រជាកសិករប្រើប្រាស់ប្រចាំថ្ងៃទេ ។





# តើត្រូវបង្កើតក្រុមការងារនេះយ៉ាងដូចម្តេច?

**ជំហានទី ១:** ជ្រើសរើសប្រធាន និងអនុប្រធានក្រុមអ្នកគ្រប់គ្រង រួចបង្កើតក្រុមពិភាក្សាអំពីស្ថានភាពរបស់ប្រជាកសិករក្នុងមូលដ្ឋាន និងលទ្ធភាពនៃការងារគ្រប់គ្រងធនធានជលផលដែលអាចធ្វើទៅបាន ។

**ជំហានទី ២:** កំណត់តំបន់ប្រព័ន្ធទឹក ដែលត្រូវគ្រប់គ្រងតាមរយៈការដើរកាត់ទទឹងភូមិ និងពិភាក្សាជាមួយប្រជាជនក្នុងភូមិ។ គ្រួសារដែលមានប្រព័ន្ធទឹកនៅក្នុងតំបន់នោះ ត្រូវបានគេកំណត់ថា ជាសមាជិកសំខាន់របស់ក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន។







**ជំហានទី ៣ :**

បន្ទាប់មក លទ្ធភាពនៃការគ្រប់គ្រង ដែលរកឃើញនៅក្នុងជំហានទី ១ ត្រូវធ្វើបទបង្ហាញទៅក្រុមផ្សេងទៀត ដើម្បីពិភាក្សា និងកំណត់រកចំនុចឯកភាពគ្នា អំពីការងារគ្រប់គ្រងដែលសមស្របបំផុត ហើយដែលពួកគេអាចយកទៅអនុវត្តបាន ។

**ជំហានទី ៤:**

ចុងក្រោយបង្អស់ ក្រោយពីក្រុមពិភាក្សាបានឯកភាពគ្នានូវតំបន់ប្រព័ន្ធទឹកដែលត្រូវគ្រប់គ្រង សមាជិកក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន ត្រូវអនុវត្តនូវការគ្រប់គ្រងក្នុងមូលដ្ឋានដែលបានឯកភាពគ្នានោះ ។

# សកម្មភាពខ្លះៗ នៃការគ្រប់គ្រងប្រព័ន្ធទឹក ដោយកសិករ



ស្តារប្រព័ន្ធប្រឡាយ ឬស្រះឱ្យជ្រៅ



ការថែបំប៉នពូជត្រីក្នុងហាប៉ា
(ក្នុងស្បៃមុងនីឡុង)



រៀបចំបង្កើតជាជម្រកត្រី



លែងប្រភេទត្រីពូជធម្មជាតិ ដើម្បីរក្សាពូជ និងបង្កើនផលត្រី



រៀបចំផ្លូវត្រីចូល ដោយដាក់ប្រើស



លែងកូនត្រីពូជក្នុងស្រះកសិករ

# ការរៀបចំ និងការអនុវត្តផែនការសកម្មភាព



ការរៀបចំផែនការត្រូវធ្វើឡើង និងសម្រេចដោយសហគមន៍ ឬក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន ។



ការរៀបចំផែនការនេះ ត្រូវមានការចូលរួមសម្របសម្រួលពីអាជ្ញាធរដែនដី ក្នុងមូលដ្ឋាន និងមន្ត្រីជលផល ឬ អង្គការនានា ។



ផែនការសកម្មភាពនេះ ត្រូវឯកភាព និងអនុវត្តដោយប្រជាពលរដ្ឋ ឬសមាជិកក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន ។

# តើស្ថានភាពនៃធនធានជលផល អាចវាយតម្លៃបានយ៉ាងដូចម្តេច ?



ធនធានជលផលតាមមូលដ្ឋានអាចធ្វើការប៉ាន់ប្រមាណបានថា កើន ឬថយចុះ ដោយផ្អែកលើស្ថានភាពនៃការប្រែប្រួលធម្មជាតិ និងសកម្មភាពប្រព្រឹត្តរបស់មនុស្ស ។ តាមការពិភាក្សាជាមួយប្រជាពលរដ្ឋព័ត៌មានសំខាន់ៗដែលប្រមូលបាន គឺជាគោលការណ៍សំខាន់ក្នុងការធ្វើសេចក្តីសន្និដ្ឋាន ចំពោះស្ថានភាពធនធានជលផល ។ តើគោលការណ៍សំខាន់ទាំងនោះមានអ្វីខ្លះ ? គឺមាន

១- កំណត់រកប្រព័ន្ធដែនទឹកធម្មជាតិផ្សេងៗគ្នា ដែលមាននៅក្នុងតំបន់នោះ

២- កំណត់រកអ្នកដែលបានធ្វើការនេសាទក្នុងតំបន់ទាំងនោះ ហើយមានប្រភេទវារីសត្វអ្វីខ្លះដែលពួកគេនេសាទបានពីតំបន់នោះ

៣-ធ្វើបញ្ជីឈ្មោះវារីសត្វទាំងអស់ដែលប្រមូលបានពីប្រព័ន្ធទឹកផ្សេងៗគ្នា

៤- ធ្វើការវិភាគ និងកំណត់រកប្រភេទវារីសត្វដែលអាចផលិត ឬប្រមូលផលបានពីតំបន់នេសាទនីមួយៗ

៥- បន្ទាប់មកធនធានវារីសត្វទាំងនោះ អាចរៀបចំទៅតាមប្រភេទនីមួយៗ អាស្រ័យទៅនឹងការចាំបាច់ ។

លទ្ធផលដែលទទួលបាន ក្រោយពីការប៉ាន់ប្រមាណធនធានជលផល ត្រូវធ្វើការបង្ហាញដល់ប្រជាពលរដ្ឋ ឬអ្នកតំណាងប្រជាជនក្នុងភូមិ និងរួមបញ្ចូលប្រជាពលរដ្ឋសំខាន់ៗ (ចាស់ព្រឹទ្ធាចារ្យ ....) ដែលអាចចូលរួមក្នុងការងារគ្រប់គ្រងធនធានជលផល ។ ក្នុងអំឡុងពេលពិភាក្សានេះព័ត៌មានដែលប្រមូលបានទាំងនោះ ត្រូវបានធ្វើការវិភាគ និងបញ្ជាក់រកភាពត្រឹមត្រូវភ្លាមៗពីប្រជាពលរដ្ឋក្នុងភូមិ ដើម្បីកែលំអការយល់ដឹងពីធនធានជលផលដែលមានក្នុងភូមិនោះ និងរកវិធីសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ឱ្យមាននិរន្តរភាព ។ តាមរយៈនៃការវាយតម្លៃនេះ ក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលអាចរកឃើញបទពិសោធន៍ល្អៗ ដើម្បីធ្វើការកែលំអផែនការគ្រប់គ្រងរបស់ខ្លួន ។

# តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីដឹងថា ការងារក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងតំបន់ មានប្រសិទ្ធភាព?






យើងអាចវាយតម្លៃការងារគ្រប់គ្រងរបស់ក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋានបាន តាមរយៈការរៀបចំប្រជុំរៀងរាល់ ១ ខែ ឬ ២ខែម្តង ដោយមានការចូលរួមពីរដ្ឋអំណាចមូលដ្ឋាន ឬមន្ត្រីជលផល ដើម្បីពិភាក្សាអំពី :-

- តើមានសកម្មភាពអ្វីខ្លះ ដែលយើងបានអនុវត្តកន្លងមក ?
- តើមានបញ្ហាអ្វីខ្លះ ដែលយើងបានជួបប្រទះកន្លងមក ?
- តើយើងបានធ្វើការអង្កេតអ្វីខ្លះ ទៅលើតំបន់ដែលយើងកំពុងគ្រប់គ្រង ?

ដោយសារមានការរៀបចំប្រជុំទៀងទាត់ យើងអាចចែករំលែកបទពិសោធន៍ ពីគ្នាទៅវិញទៅមក ពីរបៀបគ្រប់គ្រងប្រព័ន្ធទឹករបស់យើងទាំងអស់គ្នា ។

សមាជិកទាំងអស់អាចធ្វើការពិភាក្សា និងសម្រេចចិត្តនូវដំណោះស្រាយគ្រប់បញ្ហា ដែលអាចធ្វើទៅបាន ។

ដោយសារមានការប្រជុំជាទៀងទាត់ យើងអាចធ្វើការប៉ាន់ប្រមាណ នូវការផ្លាស់ប្តូរ ឬការកែលំអនូវអ្វីដែលយើងបានអនុវត្តក្នុងរយៈពេលកន្លងមក ដើម្បីធ្វើយ៉ាងណាឱ្យការងារអនុវត្តនៅពេលក្រោយ មានប្រសិទ្ធភាព។

**ខ្ញុំឆ្ងល់ថា តើហេតុអ្វីបានជាចាប់អារម្មណ៍នៅលើ ក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ?**



ព្រោះក្រុមការងារនេះជួយគ្រប់គ្រង និងបង្កើនបរិមាណធនធានជលផលនៅក្នុងតំបន់របស់យើង និងនៅក្បែរភូមិ ហើយសមាជិកក្នុងសហគមន៍នឹងបានរៀនសូត្រពីគ្នាទៅវិញ ទៅមក ពីរបៀបធ្វើការរួមគ្នា ថែមទៀតផង ។







ម្យ៉ាងទៀត យើងអាចចែករំលែកផលត្រី ឬប្រភេទវារីសត្វ ដទៃទៀតពីសមាជិកនៃក្រុមសហគមន៍ឱ្យទៅអ្នកផ្សេងទៀតក្នុងមូលដ្ឋាន ដើម្បីទុកធ្វើពូជ និងធ្វើម្ហូប ។

ព្រមទាំង ផ្តល់ឱកាសឱ្យអ្នកផ្សេងទៀតដើម្បីចូលរួមចែករំលែកបទពិសោធន៍ជាមួយសមាជិកសហគមន៍ក្នុងការងារគ្រប់គ្រងប្រព័ន្ធទឹកនានា ។

## គំរូនៃរបៀបវារៈ សម្រាប់រៀបចំការប្រជុំឆ្លៀងឆាត់ :-

១- តើមានការងាររីកចំរើនអ្វីខ្លះ របស់ក្រុមសហគមន៍ ទាក់ទងនឹងការអនុវត្តផែនការសកម្មភាព ?

- តើមានផែនការសកម្មភាពអ្វីខ្លះ ដែលបានរៀបចំកន្លងមក ?
- តើមានផែនការសកម្មភាពអ្វីខ្លះ ដែលអនុវត្តបានសម្រេច និងមិនបានសម្រេច ?
- តើអ្នកណាខ្លះជាអ្នកអនុវត្តការងារទាំងនោះ ?
- តើមានហេតុផលអ្វីខ្លះ ដែលធ្វើឱ្យមានការរីកចំរើននូវសកម្មភាពផ្សេងៗគ្នា ?

២- តើមានបញ្ហាអ្វីខ្លះដែលបានជួបប្រទះ ក្នុងពេលអនុវត្តសកម្មភាព ឬក៏មានបញ្ហាផ្សេងទៀតនៅក្នុងសហគមន៍ ?

៣- តើបានធ្វើការអង្កេតឃើញអ្វីខ្លះ នៅក្នុងប្រព័ន្ធទឹកគ្រប់គ្រងទាំងនោះ ?

៤- តើមានប្រភេទវារីសត្វអ្វីខ្លះ ដែលអ្នកចាប់បានពីប្រព័ន្ធទឹកទាំងនោះ ?

៥- តើមានប្រជាជនតំបន់ដទៃទៀតមកប្រមូលផល ( វារីសត្វ និងវារីរុក្ខជាតិ ) នៅក្នុងប្រព័ន្ធទឹកគ្រប់គ្រងនោះដែរឬទេ ?

៦- តើមានផែនការសកម្មភាពអ្វីខ្លះ សម្រាប់អនុវត្តនៅពេលក្រោយ ?

៧- តើការប្រជុំនៅពេលក្រោយ ត្រូវរៀបចំនៅពេលណា ? នៅកន្លែងណា ? ហើយមាននរណាខ្លះនឹងជួយការងារនេះ ?

## ការផ្សព្វផ្សាយសកម្មភាពការងារ សម្រាប់ការត្រួតពិនិត្យ
## ក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន

ក្រុមពិភាក្សា : ស្តាប់សមាជិកម្នាក់ៗក្នុងក្រុម នូវទស្សនៈរបស់ពួកគេអំពីស្ថានភាពគ្រប់គ្រងប្រព័ន្ធទឹកកន្លងមក ហើយសម្រាប់ឱ្យអ្នកដទៃទៀតបានរៀនសូត្រពីការពិភាក្សានេះ ។

**ចាត់ចំណាត់ថ្នាក់ :** ធ្វើចំណាត់ថ្នាក់បញ្ហា ផលប្រយោជន៍ និងសកម្មភាពការងារ ។

**រៀបចំផែនទីធនធានវារីសត្វក្នុងតំបន់ :** ដើម្បីឱ្យបានដឹងច្បាស់ពីផលិតផល ឬ ទិន្នផលជលផលផ្សេងៗគ្នា ពីប្រព័ន្ធទឹកដែលមានក្នុងភូមិ និងបានដឹងពីរបៀបប្រើប្រាស់ធនធានជលផលទាំងនោះ ។

ព័ត៌មានបន្ថែមសូមទាក់ទង : លោក : ហាវ វិសិដ្ឋ និង ជិន ដា
អ៊ីម៉ែល : smallfish@online.com.kh ទូរស័ព្ទ- ទូរសារ : 023 996 380
អាសយដ្ឋាន : នាយកដ្ឋានជលផល ភ្នំពេញ កម្ពុជា

DFID Department for International Development

ទំនាក់ទំនង : ប្រធានគ្រប់គ្រងកម្មវិធី AFGRP
អ៊ីម៉ែល : afgrp@stir.ac.uk
Website: www.dfid.stir.ac.uk/afgrp/projects/r7917/r7917.htm

-រៀបចំដោយ : ការិយាល័យវារីវប្បកម្ម នាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-សហការជាមួយ : គម្រោងការនេសាទវារីសត្វឱ្យមាននិរន្តរភាព នៃកម្មវិធីកែលំអពូជសម្រាប់ការអភិវឌ្ឍន៍ វារីវប្បកម្ម និង វិទ្យាស្ថានវារីវប្បកម្ម នៃសកលវិទ្យាល័យស្ទឺលីង ចក្រភពអង់គ្លេស

ឧបត្ថម្ភដោយ : នាយកដ្ឋានសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ នៃចក្រភពអង់គ្លេស

DFID Department for International Development

**ព័ត៌មានបន្ថែមសូមទាក់ទងមក :**


- ការិយាល័យវារីវប្បកម្ម នាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អាសយដ្ឋាន : ជីឡូតិលេខ ១៨៦ ផ្លូវនរោត្តម ប្រអប់សំបុត្រលេខ ៨៣៥ ភ្នំពេញ កម្ពុជា
- ទូរស័ព្ទ- ទូរសារលេខ : **+855 23 996 380**
- អ៊ីម៉ែល : **smallfish@online.com.kh**